ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
សំណុំរឿងរដ្ឋប្បវេណីលេខ: ៥២១
ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២
សាលក្រមលេខ: ០០២ (ថ)
ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្ដាល

-បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅសាលសវនាការនៃសាលាដំបូងខេត្តកណ្ដាល នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២២ ។

-កាលបរិច្ឆេទបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២២ ។

-កាលបរិច្ឆេទប្រកាសសាលក្រម នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង ០៩ និង ០០ នាទីព្រឹក។

**ចៅក្រម** ៖ លោក [redacted]

**ក្រឡាបញ្ជី** ៖ លោក [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងរដ្ឋប្បវេណីលេខ: ៥២១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ ដែលមានភាគីដូចខាងក្រោម ៖

១.ភាគីដើមចោទ និងជាភាគីចុងចម្លើយនៃបណ្ដឹងតប ឈ្មោះ [redacted] ធឿន ភេទ ស្រី អាយុ ៥៩ ឆ្នាំ មានអាសយដ្ឋាននៅ [redacted] ដោយមានលោកស្រីមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិអោយភាគីដើមចោទ ។

២.ភាគីចុងចម្លើយ និងជាភាគីដើមចោទនៃបណ្ដឹងតប ឈ្មោះ [redacted] អឿន ភេទ ស្រី អាយុ ៥៧ ឆ្នាំ មានអាសយដ្ឋាននៅ [redacted] ដោយមានលោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិអោយភាគីចុងចម្លើយ ។

## អង្គហេតុ និង ចំណុចវិវាទ

### ១. ខ្លឹមសារនៃសាលក្រមដែលភាគីដើមចោទនៃបណ្ដឹងដើម បានទាមទារ រួមមាន ÷

១.១. សុំឱ្យតុលាការចេញសាលក្រម សុំសិទ្ធិគ្រប់គ្រងកាន់កាប់នូវដីលំនៅដ្ឋាន ១កន្លែង មានទទឹងប្រវែង១០ម៉ែត្រ និងបណ្ដោយ ២៥ម៉ែត្រ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល ដែលមានព្រំប្រទល់ ខាងលិចទល់នឹងដី [redacted] សុខសាន្ត ខាងកើតទល់នឹងផ្លូវលំ ខាងជើងទល់នឹងដី [redacted] ស៊ុនអៀម និងខាងត្បូងទល់នឹងដី [redacted] រ៉ុង ដើម្បីឱ្យដើមចោទបានទទួលនូវសិទ្ធិដែលជាកម្មសិទ្ធិស្របច្បាប់ ។



Scanned with CamScanner

១.២. បង្គាប់ឱ្យមន្ត្រីសុរិយោដី ចុះបញ្ជីក្បាលដីលំនៅដ្ឋាន ១កន្លែងមានទទឹងប្រវែង១០ម៉ែត្រ និងបណ្តោយ ២៥ម៉ែត្រ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល មកឱ្យដើមចោទឈ្មោះ [redacted] ធឿន ។

១.៣. ឱ្យប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ។

**២. ខ្លឹមសារនៃសាលក្រមដែលភាគីដើមចោទនៃបណ្តឹងតប បានទាមទារ រួមមាន ÷**

២.១. ច្រានចោលការទាមទារទាំងអស់របស់ចុងចម្លើយតបឈ្មោះ [redacted] ធឿន លេខ ៥២១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកណ្តាល ។

២.២. ស្នើសុំឱ្យតុលាការសម្រេចបែងចែកអចលនវត្ថុ(ដី) ដែលមានទទឹង ១០ម៉ែត្រ បណ្តោយ ២៥ម៉ែត្រ សរុបទំហំ ២៥០ម៉ែត្រការ៉េ ស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ជាពីរចំណែកស្មើគ្នា ។

២.៣. បង្គាប់ឱ្យចុងចម្លើយនៃបណ្តឹងតបឈ្មោះ [redacted] ធឿន សងការខូចខាតលើការចំណាយសេវាផ្នែកច្បាប់ ចំនួន ៦,000,000៛ (ប្រាំមួយលាន) រៀល ឱ្យទៅដើមបណ្តឹងតប ។

២.៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយនៃបណ្តឹងតប ។

## អង្គហេតុដែលជាមូលហេតុនៃការទាមទារ

កាលពីឆ្នាំ១៩៩០ ឪពុកភាគីដើមចោទឈ្មោះ [redacted] រឹម និងម្តាយឈ្មោះ [redacted] យ៉ម បានទទួលរបបដីពីរដ្ឋកម្ពុជា ក្នុងទំហំ ៥០០ម៉ែត្រការ៉េ ស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩០ ដោយឪពុកម្តាយភាគីដើមចោទ មានកូនចំនួន ៥នាក់ កូនទី១ ឈ្មោះ [redacted] ថា កូនទី២ ឈ្មោះ [redacted] ធឿន កូនទី៣ ឈ្មោះ [redacted] អឿន កូនទី៤ ឈ្មោះ [redacted] អូន និងកូនទី៥ ឈ្មោះ [redacted] ថុន ។ ក្រោយមកឪពុកម្តាយភាគីដើមចោទបានធ្វើការបែងចែកដីខាងលើនេះ ជា ៣ចំណែក ដោយប្រគល់ឱ្យឈ្មោះ [redacted] អូន ចំនួន ១ប្លង់ ប្រគល់ឱ្យឈ្មោះ [redacted] ថុន ចំនួន ១ប្លង់ ហើយដីដែលនៅសល់ ១ប្លង់ទៀត មានប្រវែង ១០ម៉ែត្រ បណ្តោយ ២៥ម៉ែត្រ គឺឪពុកម្តាយ និងភាគីដើមចោទឈ្មោះ [redacted] ធឿន បានធ្វើការសាងសង់ផ្ទះឈើ និងបានស្នាក់នៅលើផ្ទះ និងដីនេះរហូតមក លុះមកដល់ឆ្នាំ២០០៦ ឪពុកភាគីដើមចោទបានទទួលមរណភាព ហើយភាគីដើមចោទក៏បន្តកាន់កាប់ស្នាក់នៅលើផ្ទះ និងដីនេះ រហូតមកដល់បច្ចុប្បន្ន ដោយឡែកឈ្មោះ [redacted] ថា និងឈ្មោះ [redacted] អឿន ដែលបានបែកលំនៅដ្ឋានទៅរស់នៅខាងក្រៅជាមួយគ្រួសារតាំងពីមុនឆ្នាំ១៩៩០ គឺពួកគាត់បានទទួលដីពីម្តាយក្នុងម្នាក់ៗ ១ប្លង់រួចហើយ។ លុះមកដល់ឆ្នាំ២០២០ ឈ្មោះ [redacted] អឿន បានមកទាមទារចំណែកដីដែលភាគីដើមចោទកំពុងកាន់កាប់ និងស្នាក់នៅអាស្រ័យផលតាំងពីឆ្នាំ១៩៩០មក ដោយទាមទារឱ្យភាគីដើមចោទបែងចែកដីឱ្យគាត់ពាក់ កណ្តាលទៅវិញ ទាំងដែលឈ្មោះ [redacted] អឿន បានទទួលដីពីម្តាយរួចហើយ។ ហើយមកដល់ពេលបច្ចុប្បន្ននេះ ដីលំនៅដ្ឋានដែលភាគីដើមចោទកំពុងតែកាន់កាប់ និងស្នាក់នៅអាស្រ័យផល មានប្រវែងទទឹង ១០ម៉ែត្រ និងបណ្តោយ ២៥ម៉ែត្រ ស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល គឺពុំទាន់មានប័ណ្ណកម្មសិទ្ធិនៅឡើយទេ



Scanned with CamScanner

ដែលជាហេតុនាំឱ្យភាគីដើមចោទមិនអាចចាត់ចែងនូវដីដែលភាគីដើមចោទកំពុងតែកាន់កាប់ដោយស្របច្បាប់នេះបាន។

## សេចក្តីថ្លែងការណ៍របស់ភាគី

**១.នៅក្នុងបណ្តឹងដើម ភាគីបានធ្វើសេចក្តីថ្លែងការណ៍ដូចតទៅ ÷**

-មេធាវីតំណាងដោយអាណត្តិរបស់ភាគីដើមចោទ និងជាភាគីចុងចម្លើយនៃបណ្តឹងតបឈ្មោះ [redacted] ធឿន បានធ្វើសេចក្តីថ្លែងការថា ទី១ ខ្លួនសុំឱ្យតុលាការចេញសាលក្រម សុំសិទ្ធិគ្រប់គ្រងកាន់កាប់នូវដីលំនៅដ្ឋាន ១កន្លែងមានទទឹងប្រវែង ១០ម៉ែត្រ និងបណ្តោយ ២៥ម៉ែត្រ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានព្រំប្រទល់ខាងលិចទល់នឹងដី [redacted] សុខសាន្ត ខាងកើតទល់នឹងផ្លូវលំ ខាងជើងទល់នឹងដី [redacted] ស៊ុនអៀម ខាងត្បូងទល់នឹងដី [redacted] រ៉ុង ដើម្បីឱ្យកូនក្តីខ្លួនបានទទួលនូវសិទ្ធិដែលជាកម្មសិទ្ធិស្របច្បាប់។ ខ្លួនសូមបញ្ជាក់ថា ដីនេះកូនក្តីខ្លួនបានរស់នៅ និងកាន់កាប់ តាំងពីឆ្នាំ១៩៩០ មកម្លេះ ដោយឪពុកម្តាយកូនក្តីរបស់ខ្លួន មានកូនចំនួន ៥នាក់ កូនទី១ ឈ្មោះ [redacted] ថា កូនទី២ ឈ្មោះ [redacted] ធឿន កូនទី៣ ឈ្មោះ [redacted] អឿន កូនទី៤ ឈ្មោះ [redacted] អូន និង កូនទី៥ ឈ្មោះ [redacted] ថុន ។ មុនពេលដែលឪពុកម្តាយកូនក្តីខ្លួនស្លាប់ គាត់បានប្រគល់ដីមួយប្លង់ឱ្យទៅឈ្មោះ [redacted] អូន និងដីមួយប្លង់ទៀត ឱ្យទៅឈ្មោះ [redacted] ថុន ចំណែកឈ្មោះ [redacted] អឿន និងឈ្មោះ [redacted] ថា បានចាកចេញពីដី ដោយមិនបានរស់នៅជាមួយឪពុកម្តាយតាំងពីឆ្នាំ១៩៩០ មកម្លេះ ប៉ុន្តែជាក់ស្តែង ឪពុកកូនក្តី របស់ខ្លួន ក៏បានចែកដីមួយប្លង់ឱ្យឈ្មោះ [redacted] ថា ផងដែរ ចំណែកឈ្មោះ [redacted] អឿន គាត់បានទទួលដីមួយប្លង់ បន្ទាប់ពីគាត់រៀបការលើកទី២រួច ដូចមានក្នុងកំណត់ហេតុបំភ្លឺរបស់ឈ្មោះ [redacted] ថា [redacted] ថុន និងឈ្មោះ [redacted] ផល នៅសាលាឃុំព្រែកអញ្ចាញ ។ ជាក់ស្តែងដីទំនាស់ដែលមានទទឹង ១០ម៉ែត្រ គុណ បណ្តោយ ២៥ម៉ែត្រ កូនក្តីរបស់ខ្លួន បានស្នាក់នៅជាមួយឪពុកម្តាយ និងមើលថែពួកគាត់ រហូតដោយមិនទាន់បានទទួលដីចំណែកមត៌កណាមួយនោះទេ ទើបឪពុកម្តាយរបស់កូនក្តីខ្លួន សម្រេចប្រគល់ដីនេះ មកឱ្យឈ្មោះ [redacted] ធឿន ដែលជាកូនក្តីរបស់ខ្លួន។ ព្រោះគាត់យល់ថា កូន ៤នាក់ផ្សេងទៀត សុទ្ធតែបានទទួលចំណែកមត៌ករួចហើយ ចាប់តាំងពីពេលដែលឪពុកកូនក្តីរបស់ខ្លួនបានស្លាប់ទៅ កូនក្តីខ្លួន ពុំទាន់បានធ្វើប័ណ្ណកម្មសិទ្ធិទៅលើដីនោះនៅឡើយទេ ប៉ុន្តែដីនេះ គឺមានពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីរបស់ឈ្មោះ [redacted] រឹម និង [redacted] យ៉ម ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩០ ។ ហេតុនេះទើបកូនក្តីខ្លួន ប្តឹងសូមមកតុលាការ ដើម្បីសុំសិទ្ធិគ្រប់គ្រងកាន់កាប់លើដីនេះ ។ ទី២ សុំឱ្យតុលាការបង្គាប់ឱ្យមន្ត្រីសុរិយោដី ចុះបញ្ជីក្បាលដីលំនៅដ្ឋាន ដែលមានទីតាំងដូចខាងលើ ឱ្យមកកូនក្តីខ្លួនឈ្មោះ [redacted] ធឿន ។ ទី៣ សុំឱ្យប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ។

-មេធាវីតំណាងដោយអាណត្តិរបស់ភាគីចុងចម្លើយ និងជាភាគីដើមចោទនៃបណ្តឹងតបឈ្មោះ [redacted] អឿន បានធ្វើសេចក្តីថ្លែងការណ៍តបថា ចំពោះចំណុចទី១ ខ្លួនសូមប្រានចោលការទាមទារទាំងអស់របស់ភាគីដើមចោទ។ ពីព្រោះ កូនក្តីរបស់ខ្លួនឈ្មោះ [redacted] អឿន ជាកូនបង្កើតរបស់ឈ្មោះ [redacted] រឹម និងឈ្មោះ [redacted] យ៉ម ដែលមានបងប្អូនសរុបចំនួន ៥នាក់ ហើយនៅក្នុងអំឡុងឆ្នាំ១៩៧៩ ឪពុក និង

ម្ដាយ បានបែងចែករបបជា ៦ចំណែក ឪពុក និងម្ដាយ ១ចំណែក និងកូនៗម្នាក់១ចំណែកស្មើគ្នា ដោយក្នុងនោះ ឈ្មោះ[redacted]ថា គាត់បានបែកគ្រួសារ ។ ក្រោយមកកូនក្ដីរបស់ខ្លួន បានរៀបការជាមួយ ឈ្មោះ [redacted] សារុំ ដោយពេលនោះ ទទួលបានដីលំនៅដ្ឋាន ១ឡូតិ៍ តែដោយសារការរស់ជាមួយប្ដីប្រពន្ធមិនមានសេចក្ដីសុខ ក៏ចែកផ្លូវគ្នាទៅ ហើយកូនក្ដីរបស់ខ្លួនក៏បានមករស់នៅជាមួយឪពុកម្ដាយបង្កើតវិញ រីឯដីលំនៅដ្ឋានដែលទទួលបានរបបពីអាជ្ញាធរនោះ ត្រូវបានគេដកហូតយកវិញ។ លុះដល់ឆ្នាំ១៩៨៦ កូនក្ដីខ្លួន បានរៀបការជាមួយឈ្មោះ [redacted] ពឿន ហើយបានបន្តរស់នៅជាមួយឪពុកម្ដាយ រហូតដល់ឆ្នាំ១៩៨៩ ។ ក្នុងឆ្នាំ១៩៩០ កូនក្ដីរបស់ខ្លួនទាំងប្ដីប្រពន្ធ បានចាក់ចេញទៅនៅភូមិតាម៉ៃ ឃុំកំពង់អុស ស្រុកពញាឮ ខេត្តកណ្ដាល ដោយទុកដីឱ្យប្អូនស្រីឈ្មោះ[redacted] អូន ស្នាក់នៅ ទើបមកដល់ឆ្នាំ ១៩៩២ កូនក្ដីរបស់ខ្លួនទាំងប្ដីប្រពន្ធត្រលប់មកផ្ទះ ដែលបានទិញ ដើម្បីបន្តស្នាក់នៅរហូតមកដល់សព្វថ្ងៃនេះ ។ នៅអំឡុងឆ្នាំ ១៩៨៦ កូនក្ដីរបស់ខ្លួន បានរៀបការជាមួយឈ្មោះ [redacted] ពឿន ហើយតាំងពីឆ្នាំ១៩៨៧ រហូតដល់ឆ្នាំ១៩៩៧ កូនក្ដីខ្លួនមិនបានទទួលដីឡូតិ៍ នៅក្នុងលំនៅដ្ឋាន ភូមិសំរោងនោះទេ ចំណែកដីដែលបានចែកជារបបពីមុននោះ ត្រូវបានគេដកហូតយកទៅវិញដែរ។ ចំពោះផ្ទះ និងដីលំនៅដ្ឋាន ដែលរស់នៅសព្វថ្ងៃនេះ គឺកូនក្ដីខ្លួនទាំងប្ដីប្រពន្ធ បានទិញពីឈ្មោះ ប្ដីប្រពន្ធ [redacted] ធីម ក្នុងតម្លៃ ៥ជីនៅឆ្នាំ១៩៨៨ ។ របបដែលឪពុកម្ដាយចែកមួយចំណែកស្មើៗគ្នា កូនក្ដីខ្លួន មិនបានទទួលទេ ចំពោះបងប្អូនផ្សេងៗ បានទទួលចំណែករៀងៗខ្លួនរួចហើយ ។ ចំពោះចំណុចទី២ ដែលភាគីតំណាងដើមចោទបាន ស្នើសុំឱ្យតុលាការបង្គាប់ឱ្យមន្ត្រីសុរិយោដី ចុះបញ្ជីក្បាលដីលំនៅដ្ឋាន ដែលមានទីតាំងដូចខាងលើ ឱ្យមកកូនក្ដីខ្លួនឈ្មោះ[redacted] ធឿន ខ្លួនសូមប្រានចោលនូវការទាមទាររបស់មេធាវីខាងលើ ។ ចំណែកចំណុចទី៣ ដែលភាគីតំណាងដើមចោទបានស្នើសុំឱ្យប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីចុងចម្លើយនោះ គឺខ្លួនសូមឱ្យតុលាការសម្រេចទៅតាមច្បាប់ ។

**២.នៅក្នុងបណ្ដឹងតប ភាគីបានធ្វើសេចក្ដីថ្លែងការណ៍ដូចតទៅ៖**

-មេធាវីតំណាងដោយអាណត្តិរបស់ភាគីចុងចម្លើយ និងជាភាគីដើមចោទនៃបណ្ដឹងតប ឈ្មោះ[redacted]អឿន បានធ្វើសេចក្ដីថ្លែងការណ៍នៅក្នុងបណ្ដឹងតបថា ចំណុចទី១ ខ្លួនសូមប្រានចោលការទាមទារទាំងអស់របស់ភាគីដើមចោទ ដូចមានៅក្នុងសេចក្ដីថ្លែងការណ៍ខាងលើ ។ ពីព្រោះ កូនក្ដីរបស់ខ្លួនឈ្មោះ[redacted]អឿន ជាកូនបង្កើតរបស់ឈ្មោះ[redacted]រឹម និងឈ្មោះ [redacted] យ៉ម ដែលមានបងប្អូនសរុបចំនួន ៥នាក់ ហើយនៅក្នុងអំឡុងឆ្នាំ១៩៧៩ ឪពុក និងម្ដាយ បានបែងចែករបបជា ៦ចំណែក ឪពុក និងម្ដាយ ១ចំណែក និងកូនៗម្នាក់ ១ចំណែកស្មើគ្នា ដោយក្នុងនោះ ឈ្មោះ[redacted]ថា គាត់បានបែកគ្រួសារ។ ក្រោយមកកូនក្ដីរបស់ខ្លួន បានរៀបការជាមួយឈ្មោះ[redacted]សារុំ ដោយពេលនោះ ទទួលបានដីលំនៅដ្ឋាន ១ឡូតិ៍ តែដោយសារការរស់ជាមួយប្ដីប្រពន្ធមិនមានសេចក្ដីសុខ ក៏ចែកផ្លូវគ្នាទៅ ហើយកូនក្ដីរបស់ខ្លួនក៏បានមករស់នៅជាមួយឪពុកម្ដាយបង្កើតវិញ រីឯដីលំនៅដ្ឋានដែលទទួលបានរបបពីអាជ្ញាធរនោះ ត្រូវបានគេដកហូតយកវិញ ។ លុះដល់ឆ្នាំ១៩៨៦ កូនក្ដីខ្លួន បានរៀបការជាមួយឈ្មោះ[redacted]ពឿន ហើយបានបន្តរស់នៅជាមួយឪពុកម្ដាយ រហូតដល់ឆ្នាំ១៩៨៩ ។ ក្នុងឆ្នាំ១៩៩០ កូនក្ដីរបស់ខ្លួនទាំងប្ដីប្រពន្ធ បានចាក់ចេញទៅនៅភូមិតាម៉ៃ ឃុំកំពង់អុស ស្រុកពញាឮ ខេត្តកណ្ដាល ដោយទុកដីឱ្យប្អូនស្រី

ឈ្មោះ[redacted]អូន ស្នាក់នៅ ទើបមកដល់ឆ្នាំ១៩៩២ កូនក្តីរបស់ខ្លួនទាំងប្តីប្រពន្ធត្រលប់មកផ្ទះ ដែលបានទិញ ដើម្បីបន្តស្នាក់នៅរហូតមកដល់សព្វថ្ងៃនេះ ។ នៅអំឡុងឆ្នាំ ១៩៨៦ កូនក្តីរបស់ខ្លួន បានរៀបការជាមួយឈ្មោះ [redacted] ពឿន ហើយតាំងពីឆ្នាំ១៩៨៧ រហូតដល់ឆ្នាំ១៩៩៧ កូនក្តីខ្លួនមិនបានទទួលដីឡូតិ៍នៅក្នុងលំនៅដ្ឋាន ភូមិសំរោងនោះទេ ចំណែកដីដែលបានចែកជារបបពីមុននោះ ត្រូវបានគេដកហូតយកទៅវិញដែរ។ ចំពោះផ្ទះ និងដីលំនៅដ្ឋាន ដែលរស់នៅសព្វថ្ងៃនេះ គឺកូនក្តីខ្លួនទាំងប្តីប្រពន្ធ បានទិញពីឈ្មោះ ប្តីប្រពន្ធ [redacted] ធីម ក្នុងតម្លៃ ៥ជី នៅឆ្នាំ១៩៨៨ ។ របបដែលឪពុកម្តាយចែកមួយចំណែកស្មើៗគ្នា កូនក្តីខ្លួន មិនបានទទួលទេ  ចំពោះបងប្អូនផ្សេងៗ បានទទួលចំណែករៀងៗខ្លួនរួចហើយ។ ខ្លួនសូមបញ្ជាក់ថា នៅក្នុងឆ្នាំ២០១៦ លោកឪពុកកូនក្តីរបស់ខ្លួនឈ្មោះ[redacted]រឹម បានធ្វើការបែងចែកកេរមត៌កដីលំនៅដ្ឋានមួយកន្លែង ដែលមានបណ្តោយ ១៩.១០ម៉ែត្រ និងទទឹង ១០.២០ម៉ែត្រ សរុប ១៩៤.៨២ ម៉ែត្រការ៉េ ដែលឱ្យទៅឈ្មោះ ប្តីប្រពន្ធ [redacted]ថល និង [redacted]អូន ដែលត្រូវជាកូនបង្កើត និងកូនប្រសារ។ ទី២ ស្នើសុំឱ្យតុលាការសម្រេចបែងចែកអចលនវត្ថុ(ដី) ដែលមានទទឹង ១០ម៉ែត្រ បណ្តោយ ២៥ម៉ែត្រ សរុបទំហំ ២៥០ម៉ែត្រការ៉េ ស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ជាពីរចំណែកស្មើគ្នា ។ ទី៣ បង្គាប់ឱ្យចុងចម្លើយនៃបណ្តឹងតបឈ្មោះ[redacted]ធឿន សង់ការខូចខាតលើការចំណាយសេវាផ្នែកច្បាប់ ចំនួន ៦,០០០,០០០ រៀល ឱ្យទៅដើមបណ្តឹងតប។ ទី៤ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយនៃបណ្តឹងតប។

-មេធាវីតំណាងដោយអាណត្តិរបស់ភាគីដើមចោទ និងជាភាគីចុងចម្លើយនៃបណ្តឹងតបឈ្មោះ[redacted]ធឿន បានធ្វើសេចក្តីថ្លែងការណ៍តបវិញថា ចំណុចទី១ ខ្លួនសូមរក្សាការទាមទារដូចមាននៅក្នុងពាក្យបណ្តឹងដដែល។ ចំណុចទី២ ខ្លួនតំណាងឱ្យកូនក្តីឈ្មោះ[redacted] ធឿន សូមធ្វើការបដិសេធននូវការទាមទារត្រង់ចំណុចនេះ ដោយមានមូលហេតុថា កន្លងមកឈ្មោះ[redacted] អឿន និងឈ្មោះ [redacted] ពឿន បានទទួលដីមួយកន្លែងពីឪពុកឈ្មោះ [redacted] រឹម និងម្តាយឈ្មោះ [redacted] យ៉ម រួចហើយ ដោយកាលនោះឈ្មោះ[redacted] រឹម ជាអ្នកទៅទំនាក់ទំនងជាមួយនឹងលោកមេឃុំឈ្មោះ [redacted]ឆាន ដើម្បីសុំយកដី និងផ្ទះមួយកន្លែង ដែលពីមុនជារបស់ឈ្មោះ [redacted] ធីម និងឈ្មោះ ទូច តែអ្នកទាំងពីរបានចាកចេញទៅរស់នៅកំពង់សោម ទើបឪពុកឈ្មោះ[redacted]រឹម ទៅសុំដី និងផ្ទះនោះពីប្រធានភូមិ ដោយប៉ះប៉ូវជាថ្នូរនឹងមាសមួយចំនួនដូចមានបញ្ជាក់ក្នុងកំណត់ហេតុបំភ្លឺរបស់ឈ្មោះ[redacted]ថា ឈ្មោះ [redacted] ថុន និងឈ្មោះ [redacted]ថល នៅសាលាឃុំព្រែកអញ្ចាញ។ ចំពោះចំណុចទី៣ និងទី៤ នៃបណ្តឹងតបខាងលើ ខ្លួនសូមធ្វើការបដិសេធន៍នូវការទាមទារនេះ ។

## ចំណុចវិវាទ

តើដីលំនៅដ្ឋាន ១កន្លែងដែលមានទទឹងប្រវែង ១០ម៉ែត្រ និងបណ្តោយ ២៥ម៉ែត្រ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានព្រំប្រទល់ខាងលិចទល់នឹងដី [redacted] សុខសាន្ត ខាងកើតទល់នឹងផ្លូវលំ ខាងជើងទល់នឹងដី[redacted] ស៊ុនអៀម និងខាងត្បូងទល់នឹងដី[redacted] រ៉ុង ជាដីចំណែកកេរ្តិ៍មត៌ករបស់ភាគីដើមចោទ ឬជាដីចំណែកកេរ្តិ៍មត៌ករួម?

## សំអាងហេតុ

ឆ្លងកាត់តាមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ព្រមទាំងក្រោយពីបានពិចារណាត្រឹមត្រូវតាមផ្លូវច្បាប់រួចហើយ តុលាការយល់ឃើញថា៖

១. ពាក្យបណ្តឹងលេខ: ៥២១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ និងពាក្យបណ្តឹងតបលេខ: ០១២ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ដែលអាចលើកយកមកពិចារណា និងសម្រេចសេចក្តី ។

២. តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យភាគីដើមចោទ និងមេធាវីតំណាងដោយអាណត្តិឱ្យភាគីចុងចម្លើយ បានបង្ហាញឱ្យឃើញថា ដីលំនៅដ្ឋាន ចំនួន ១កន្លែង មានទទឹងប្រវែង ១០ម៉ែត្រ និង បណ្តោយប្រវែង ២៥ម៉ែត្រ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល មានព្រំប្រទល់ខាងលិចទល់នឹងដី [redacted] សុខសាន្ត ខាងកើតទល់នឹងផ្លូវលំ ខាងជើងទល់នឹងដី [redacted] ស៊ុនអៀម និង ខាងត្បូងទល់នឹងដី [redacted] រ៉ុង ជារបស់ឈ្មោះ [redacted] រឹម ភេទ ប្រុស និងឈ្មោះ [redacted] យ៉ម ភេទ ស្រី ដែលត្រូវជាឪពុកម្តាយរបស់ឈ្មោះ [redacted] ថា ឈ្មោះ [redacted] ធឿន ឈ្មោះ [redacted] អឿន ឈ្មោះ [redacted] អួន និងឈ្មោះ [redacted] ថុន ដែលបច្ចុប្បន្នពួកគាត់ទាំងពីរនាក់ បានទទួលមរណភាពរួចទៅហើយ ដោយនៅពេលពួកគាត់ទាំងពីរ នៅរស់រានមានជីវិត គឺបានចែកដី និងទ្រព្យសម្បត្តិផ្សេងៗទៀត ឱ្យទៅកូន ឈ្មោះ [redacted] ថា ឈ្មោះ [redacted] អឿន ឈ្មោះ [redacted] អួន និងឈ្មោះ [redacted] ថុន រួចអស់ នៅឡើយតែកូនឈ្មោះ [redacted] ធឿន មិនទាន់ត្រូវបានចែកទ្រព្យចំណែកមរតកនឹងគេនោះទេ ដោយសារតែកូនឈ្មោះ [redacted] ធឿន នេះ រស់នៅជាមួយនឹងឪពុកម្តាយខាងលើ ទើបឪពុកម្តាយមិនទាន់ចែកឱ្យ ដោយទុកដីលំនៅដ្ឋាន ចំនួន ១កន្លែង មានទទឹងប្រវែង ១០ម៉ែត្រ និង បណ្តោយប្រវែង ២៥ម៉ែត្រ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល មានព្រំប្រទល់ខាងលិចទល់នឹងដី [redacted] សុខសាន្ត ខាងកើតទល់នឹងផ្លូវលំ ខាងជើងទល់នឹងដី [redacted] ស៊ុនអៀម និង ខាងត្បូងទល់នឹងដី [redacted] រ៉ុង ជារបស់ឈ្មោះ [redacted] រឹម ភេទ ប្រុស និងឈ្មោះ [redacted] យ៉ម ភេទ ស្រី ឱ្យទៅឈ្មោះ [redacted] ធឿន យ៉ាងដូច្នេះ។

៣. ការសាកសួរភាគី និងនីតិវិធីនៃការពិនិត្យភស្តុតាង៖

៣.១. ការសាកសួរភាគី:

៣.១.១. ការសាកសួរភាគីដើមចោទឈ្មោះ [redacted] ធឿន

នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ភាគីដើមចោទឈ្មោះ [redacted] ធឿន បានអះអាងថា ដីលំនៅដ្ឋាន ចំនួន ១កន្លែង មានទទឹងប្រវែង ១០ម៉ែត្រ និង បណ្តោយប្រវែង ២៥ម៉ែត្រ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ជាដីរបស់ម៉ែឪរបស់ខ្លួន ប៉ុន្តែម៉ែឪរស់នៅជាមួយខ្លួន ដោយគាត់បានចែកដីនេះមកឱ្យខ្លួន ។ ខ្លួនមានបងប្អូនចំនួន ៥នាក់ ដោយទ្រព្យរបស់ឪពុកម្តាយរបស់ខ្លួន បានចែកឱ្យកូនគ្រប់គ្នាអស់ហើយ ដោយនៅតែខ្លួនតែម្នាក់ប៉ុណ្ណោះដែលមិនទាន់បានទ្រព្យចំណែកនឹងគេ ដោយទ្រព្យដីចំណែកខាងលើ គឺឪពុកម្តាយរបស់ខ្លួនចែកមកឱ្យខ្លួនតែម្នាក់



Scanned with CamScanner

គត ។ ភាគីចុងចម្លើយឈ្មោះ[redacted]ធឿន គឺឪពុកម្ដាយរបស់ខ្លួន បានចែកដីផ្សេងឱ្យគាត់ហើយ ដោយដីរបស់ខ្លួន មានលិខិតកាន់កាប់ និងបង្កាប់ដៃជារបស់ម្ដាយខ្លួន ដោយគាត់បានឱ្យមកខ្លួនជាអ្នករក្សាទុក។

៣.១.២. ការសាកសួរភាគីចុងចម្លើយឈ្មោះ[redacted]អឿន

នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ភាគីចុងចម្លើយឈ្មោះ[redacted]អឿន បានអះអាងថា ដីមួយឡូតិ៍ បណ្ដោយទំហំ ៧០ម៉ែត្រ និងទទឹងទំហំ ១០ម៉ែត្រ មានតាំងពីឆ្នាំ១៩៧៩ គឺឪពុកម្ដាយរបស់ខ្លួនចែកឱ្យកូនៗទាំងអស់គ្នា ដោយដីចំនួន ១កង់ ឈ្មោះ[redacted]ថុន និងឈ្មោះ[redacted]យ៉ម បានលក់ឱ្យគេអស់ហើយ ហើយដីខាងលើ គឺឪពុកម្ដាយរបស់ខ្លួន បានចែកមកឱ្យខ្លួន និងឈ្មោះ[redacted]ធឿន ដោយបងប្អូនចំនួន ៣នាក់ទៀត មិនបានដឹងទេ។ ដីនោះ ជាដីរបស់ខ្លួន តាំងពីឆ្នាំ១៩៧៩ ហើយដីនោះជារបបដីរបស់ខ្លួន។ ដីចែកជា ៦ចំណែកនោះ បងប្អូនដឹងទាំងអស់គ្នា ដោយឡែកដីចំណែករបស់ខ្លួន គឺបងប្អូនបានដឹងដូចគ្នា។ ខ្លួននៅជាមួយឪពុកម្ដាយតាំងតែពីឆ្នាំ១៩៨៨ ដោយរស់នៅបាន ៣ឆ្នាំ ខ្លួនក៏បែកលំនៅតែម្ដង ។ ឪម៉ែរបស់ខ្លួន មិនបានទិញដីឱ្យខ្លួននោះទេ ដោយដីដែលខ្លួនរស់នៅសព្វថ្ងៃ ជាដីដែលម៉ែឪខាងប្ដីជាអ្នកទិញឱ្យខ្លួន និងប្ដីក្រោយ។

៣.២. ការសាកសួរសាក្សី៖

៣.២.១. ការសាកសួរសាក្សីឈ្មោះ[redacted]ថា

តាមការសាកសួរសាក្សីឈ្មោះ[redacted]ថា ភេទ ប្រុស ដែលត្រូវជាកូនទី១របស់ឈ្មោះ[redacted]រឹម និងឈ្មោះ[redacted] យ៉ម បានបញ្ជាក់ថា ម៉ែឪរបស់ខ្លួន បានទិញដីឱ្យចុងចម្លើយឈ្មោះ[redacted]អឿន រួចហើយ ដោយដីចំណែករបស់ខ្លួន គឺអង្គការចែកឱ្យ។ ឪម៉ែបានចែកដីឱ្យ ២នាក់ខាងក្រៅដូចគ្នា ដោយដីដែលមានទំនាស់ ជាដីរបស់ភាគីដើមចោទឈ្មោះ[redacted]ធឿន តែម្នាក់ទេ។ ដី និងផ្ទះ គឺឪម៉ែខ្លួន ចែកឱ្យតែដើមចោទម្នាក់ឯងទេ ដោយចុងចម្លើយបានទទួលដីចំណែករបស់ខ្លួនរួចហើយ ឪពុកម្ដាយរបស់ខ្លួន បានប្រាប់ខ្លួន និងកូនៗទាំងអស់ផងដែរ។ ខ្លួនជាកូនបងគេ។

៣.២.២. ការសាកសួរសាក្សីឈ្មោះ[redacted]ថុន

តាមការសាកសួរសាក្សីឈ្មោះ[redacted] ថុន ភេទ ប្រុស ដែលត្រូវជាកូនទី៥(កូនពៅ) របស់ឈ្មោះ[redacted] រឹម និងឈ្មោះ [redacted] យ៉ម បានបញ្ជាក់ថា ម៉ែឪរបស់ខ្លួន ចែកដីទំនាស់ខាងលើឱ្យឈ្មោះ[redacted]ធឿន ឱ្យទៅតែម្នាក់ទេ ដោយសារតែចុងចម្លើយបានដីរួចហើយ ដោយឪម៉ែបានឱ្យលុយចុងចម្លើយទិញដីរួចហើយ ហើយពេលដែលឪម៉ែចែកដីឱ្យដើមចោទ គឺបងប្អូនទាំងអស់គ្នាបានដឹង រួមទាំងភាគីចុងចម្លើយផងដែរ ហើយខ្លួនមិនកាន់ជើងនរណាទេ ដោយបងប្អូនដូចគ្នា។

៣.២.៣. ការសាកសួរសាក្សីឈ្មោះ[redacted]អូន

តាមការសាកសួរសាក្សីឈ្មោះ[redacted]អូន ភេទ ស្រី ដែលត្រូវជាកូនទី៤របស់ឈ្មោះ [redacted] រឹម និងឈ្មោះ [redacted] យ៉ម បានបញ្ជាក់ថា ពួកគាត់ឈ្លោះគ្នារឿងដី និងផ្ទះ ដែលដីនោះពីដើមជារបស់ម៉ែឪខ្លួន បន្ទាប់មកគាត់ប្រគល់ឱ្យឈ្មោះ[redacted]ធឿន ដោយឈ្មោះ[redacted]ធឿន ជាអ្នកចិញ្ចឹមម៉ែឪ ហើយដីនោះ

ប្រគល់ឱ្យតែឈ្មោះ [redacted] ធឿន តែម្នាក់ទេ ដោយសារតែចុងចម្លើយចេញផុតទៅរស់នៅផ្សេងទៅហើយ។ ម៉ែឪខ្លួន បានទិញដីចែកឱ្យទៅភាគីចុងចម្លើយរួចហើយ នៅពេលប្រគល់ដីឱ្យឈ្មោះ [redacted] ធឿន គឺបងប្អូន និងចុងចម្លើយដឹងទាំងអស់គ្នា។

៣.២.៤. ការសាកសួរសាក្សីឈ្មោះ [redacted] ទូច

តាមការសាកសួរសាក្សីឈ្មោះ [redacted] ទូច ភេទ ស្រី បានបញ្ជាក់ថា ខ្លួនបានលក់ដី និងផ្ទះ ឱ្យទៅចុងចម្លើយប្រាកដមែន ដោយរឿងផ្សេងខ្លួនមិនបានដឹងនោះទេ។

៣.៣. នីតិវិធីនៃការពិនិត្យកស្តុតាង:

នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការបានពិនិត្យទៅលើភស្តុតាងជាឯកសាររួមមាន៖ ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីរបស់ឈ្មោះ [redacted] វីម និងឈ្មោះ [redacted] យ៉ម ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩០, បង្កាន់ដៃទទួលពាក្យចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៩០, កំណត់ហេតុសាកសួរឈ្មោះ [redacted] ផល, ឈ្មោះ [redacted] ថា និងឈ្មោះ [redacted] ថុន ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១ របស់សាលាឃុំព្រែកអញ្ចាញ គឺបានបញ្ជាក់ឱ្យឃើញថា ដីលំនៅដ្ឋាន ចំនួន ០១កន្លែង ដែលមានទទឹងប្រវែង ១០ម៉ែត្រ និងបណ្តោយ ២៥ម៉ែត្រ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានព្រំប្រទល់ខាងលិចទល់នឹងដី [redacted] សុខសាន្ត ខាងកើតទល់នឹងផ្លូវលំ ខាងជើងទល់នឹងដី [redacted] ស៊ុនអៀម និងខាងត្បូងទល់នឹងដី [redacted] រ៉ុង ជាដីកម្មសិទ្ធិរបស់ឈ្មោះ [redacted] វីម និងឈ្មោះ [redacted] យ៉ម ដែលបានចែកទៅឱ្យឈ្មោះ [redacted] ធឿន ភេទ ស្រី អាយុ ៥៩ឆ្នាំ រស់នៅ [redacted] ជាកូន ពិតប្រាកដមែន ។

៣.៤. ផ្អែកតាមចំណុច ៣.១, ៣.២ និង ៣.៣ ធ្វើឱ្យតុលាការជឿបានថា ដីលំនៅដ្ឋាន ចំនួន ០១កន្លែង ដែលមានទទឹងប្រវែង ១០ម៉ែត្រ និងបណ្តោយ ២៥ម៉ែត្រ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានព្រំប្រទល់ខាងលិចទល់នឹងដី [redacted] សុខសាន្ត ខាងកើតទល់នឹងផ្លូវលំ ខាងជើងទល់នឹងដី [redacted] ស៊ុនអៀម និងខាងត្បូងទល់នឹងដី [redacted] រ៉ុង ជាដីកម្មសិទ្ធិរបស់ឈ្មោះ [redacted] ម និងឈ្មោះ [redacted] យ៉ម ដែលរដ្ឋបានចែកឱ្យ ហើយមកបុគ្គលទាំងពីរបានប្រគល់ និងចែកដីចំណែកនេះ ទៅឱ្យភាគីដើមចោទឈ្មោះ [redacted] ធឿន ភេទ ស្រី អាយុ ៥៩ឆ្នាំ ដែលត្រូវជាសន្តិជនរបស់ខ្លួនដែលរស់នៅ [redacted] ពិតប្រាកដមែន គប្បីតុលាការទទួលស្គាល់សម្រេចតាមការទាមទាររបស់ភាគីដើមចោទនៅក្នុងពាក្យបណ្តឹងលេខៈ ៥២១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ និង សម្រេចច្រានចោលពាក្យបណ្តឹងតបរបស់ភាគីដើមចោទនៃបណ្តឹងតបលេខៈ ០១២ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ ។

៤. ភាគីខាងដើមចោទមិនទាមទារសងជំងឺចិត្តទៅលើភាគីចុងចម្លើយនោះទេ គប្បីតុលាការមិនធ្វើការពិចារណាអំពីសំណងនៃការខូចខាតនេះឡើយ ។



Scanned with CamScanner

៥. ផ្អែកតាមបញ្ញត្តិមាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលបានចែងថា ពន្ធជាបន្ទុករបស់អ្នកចាញ់ក្តី ។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១. ប្រគល់សិទ្ធិគ្រប់គ្រងកាន់កាប់នូវដីលំនៅដ្ឋាន ចំនួន ១កន្លែង មានទទឹងប្រវែង ១០ម៉ែត្រ និងបណ្តោយ ២៥ម៉ែត្រ មានទីតាំងស្ថិតនៅភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានព្រំប្រទល់ខាងលិចទល់នឹងដី [redacted] សុខសាន្ត ខាងកើតទល់នឹងផ្លូវលំ ខាងជើងទល់នឹងដី [redacted] ស៊ុនអៀម ខាងត្បូងទល់នឹងដី [redacted] រ៉ុង ឱ្យភាគីដើមចោទឈ្មោះ [redacted] ធឿន ភេទ ស្រី អាយុ ៥៩ឆ្នាំ ជាម្ចាស់ស្របច្បាប់ ។

២. បង្គាប់ឱ្យដើមចោទឈ្មោះ [redacted] ធឿន ធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុ(ដី) ទៅមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដីខេត្តកណ្តាល ។

៣. ច្រានចោលពាក្យបណ្តឹងតបលេខៈ ០១២ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ របស់ភាគីដើមចោទនៃបណ្តឹងឈ្មោះ [redacted] អឿន លើចំណុចនៃការទាមទារទាំងមូល ។

៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយឈ្មោះ [redacted] អឿន ភេទ ស្រី អាយុ ៥៧ឆ្នាំ ។

សាលក្រមនេះ បានទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ ចំពោះមុខគូភាគី ។

*បើកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់ ។*

ថ្ងៃចន្ទ ១០រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦
កណ្តាល ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣

**ហត្ថលេខា និងត្រា** [redacted]

---

**បានឃើញ**
**ចៅក្រម**
[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃចន្ទ ១០រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦
កណ្តាល ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣
**ក្រឡាបញ្ជី**
[redacted]